# សុន្ទរកថាបើក

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## និងជាប្រធាន គ.ជ.អ.ប

## ក្នុងកិច្ចប្រជុំលើកទី១៨ របស់ គ.ជ.អ.ប

ថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០

សាលប្រជុំក្រសួងមហាផ្ទៃ

- **ឯកឧត្តម លោកជំទាវសមាជិក សមាជិកា គ.ជ.អ.ប.**
- **ឯកឧត្តម លោកជំទាវទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ជាទីមេត្រី!**

ជាបឋម ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម លោកជំទាវសមាជិក សមាជិកា គ.ជ.អ.ប ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី១៨ របស់ គ.ជ.អ.ប នាពេលនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដែលបានយកចិត្តទុកដាក់ចូលរួម និងគាំទ្រកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដ៏មានសារៈសំខាន់នេះ តាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

ជារួម ក្នុងរយៈពេល៦ខែដើមឆ្នាំ២០២០នេះ ទោះបីយើងស្ថិតក្នុងស្ថានភាពដ៏លំបាកដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ ក៏យើងបានរួមសហការគ្នារៀបចំ និងអនុវត្តកិច្ចការជាអាទិភាព និងចាំបាច់នានា ដែលធ្វើឱ្យយើងទទួលបានលទ្ធផលប្រកបដោយជោគជ័យនៅក្នុងការប្រយុទ្ធប្រឆាំងជំងឺដ៏កាចសាហាវនេះ ព្រមទាំងរក្សាបាននូវនិរន្តរភាពនៃការបំពេញការងារតាមវិស័យជំនាញនានា ដោយផ្សារភ្ជាប់ជាមួយនឹងការជំរុញនូវកិច្ចដំណើរការកំណែទម្រង់នានាផងដែរ។

ការកោះប្រជុំលើកទី១៨របស់ គ.ជ.អ.ប. នាពេលនេះ គឺក្នុងគោលបំណងពិនិត្យឡើងវិញនូវវឌ្ឍនភាព ជាពិសេសលើបញ្ហាប្រឈមនានានៃកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលតម្រូវឱ្យយើងទាំងអស់គ្នាត្រូវបន្តដោះស្រាយជាមួយនឹងស្ថានភាពដែល ពិបាកនឹងព្យាករណ៍អំពីផលប៉ះពាល់ជាអវិជ្ជមាននៃជំងឺកូវីដ-១៩ ទៅលើសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសយើងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

នៅចុងឆ្នាំ២០១៩កន្លងមកនេះ រាជរដ្ឋាភិបាលបានសម្រេចផ្ទេរមុខងារសំខាន់ៗមួយចំនួន ជាពិសេស មុខងារក្នុងវិស័យសុខាភិបាល និងអប់រំឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលអាចកំណត់បានថា ជាសមិទ្ធផល និងជារបត់ជាប្រវត្តិសាស្រ្តនៃកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ចរបស់យើង។

អំឡុងពេល៦ខែដើមឆ្នាំនេះ យើងបានរួមសហការគ្នាសម្រេចបាននូវកិច្ចការជាច្រើននៃផែនការសកម្មភាពដែលយើងបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំលើកទី១៧របស់ គ.ជ.អ.ប.មុននេះ ដើម្បីជានាដល់ការរៀបចំ និងការប្រព្រឹត្តទៅនៃរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក៏ដោយ ក៏យើងនៅមានបញ្ហាប្រឈមមួយចំនួន ជាពិសេសបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងកិច្ចដំណើរការនៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលយើងត្រូវបន្តដោះស្រាយ។

ដោយឡែក នាពេលថ្មីៗកន្លងមកនេះ រាជរដ្ឋាភិបាលបានសម្រេចកែសម្រួលសមាសភាព គ.ជ.អ.ប ដោយបានកែសម្រួល និងបន្ថែមសមាសភាពថ្នាក់ដឹកនាំថ្មីៗមួយចំនួនក្នុងគោលបំណងលើកកម្ពស់នូវប្រសិទ្ធភាពនៃការដឹកនាំ សម្របសម្រួលកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ជាការពិតណាស់ ប្រសិទ្ធភាពនៃការដឹកនាំរបស់ គ.ជ.អ.ប.ក៏អាស្រ័យមួយចំណែកទៅលើការរៀបចំនូវអនុគណៈកម្មាធិការ និងយន្តការនានារបស់ខ្លួនឱ្យមានភាពរឹងមាំផងដែរ។

អាស្រ័យហេតុនេះ ក្នុងកិច្ចប្រជុំលើកនេះ ខ្ញុំសូមស្នើនូវរបៀបវារៈដូចខាងក្រោម៖

១. ការពិនិត្យ និងអនុម័តលើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំលើកទី១៧របស់ គ.ជ.អ.ប.
២. ការពិនិត្យពិភាក្សាលើការរៀបចំឡើងវិញនូវអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប.
៣. ការពិនិត្យពិភាក្សាលើវឌ្ឍនភាព និងបញ្ហាប្រឈមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងក្របខ័ណ្ឌនៃមុខងារ និងរចនាសម្ព័ន្ធថ្មីរបស់ខ្លួន
៤. បញ្ហាផ្សេងៗ (ប្រសិនបើមាន)

ខ្ញុំសូមបញ្ចប់នូវមតិបើកកិច្ចប្រជុំរបស់យើង និងសូមស្នើឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃ គ.ជ.អ.ប ផ្តល់យោបល់ទៅលើរបៀបវារៈខាងលើនេះ។

**សូមអរគុណ!**